# មេរៀនទី ៣៩: ព្រះយកចិត្តទុកដាក់ចំពោះហាការ និងអ៊ីសម៉ាអែល

## លោកុប្បត្តិ ២១:៨-២១

**គោលបំណង៖** ព្រះតែងតែស្តាប់ឮនៅពេលដែលយើងអធិស្ឋាន។

**ខគម្ពីរចងចាំ៖ យ៉ូហាន ១៥:៧** *"បើអ្នករាល់គ្នានៅជាប់នឹងខ្ញុំ ហើយពាក្យខ្ញុំនៅជាប់ក្នុងអ្នករាល់គ្នា នោះចូរសូមអ្វីតាមតែប្រាថ្នាចុះ សេចក្តីនោះនឹងបានសំរេចដល់អ្នករាល់គ្នាជាមិនខាន។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

ដោយសារតែព្រះយេស៊ូវ ទើបយើងអាចដឹងបានថាព្រះគឺតែងតែស្តាប់ពួកយើង។ ព្រះយេស៊ូវត្រូវបានបញ្ជូនមកដើម្បីបង្ហាញពីព្រះចេស្តានៃព្រះ ក្នុងការបំពេញសេចក្តីត្រូវការរបស់យើង មុនពេលយើងសុំពីទ្រង់ទៅទៀត។ សូមគិតអំពីពេលវេលាមួយដែលវាពិបាកសម្រាប់អ្នក។ ក្នុងអំឡុងពេលនោះ តើអ្នកបានស្វែងរកជំនួយពីព្រះ ឬមានអារម្មណ៍ថាមានវត្តមានរបស់ទ្រង់ឬទេ? ឬវាពិបាកសម្រាប់អ្នកក្នុងការដាក់ការទុកចិត្តទៅលើព្រះ? សូមអធិស្ឋានអំពីបញ្ហាដែលអ្នកកំពុងប្រឈមមុខនៅពេលនេះ។ ចូរសូមឱ្យព្រះបើកសម្តែងពីវិធីដែលបង្ហាញថាទ្រង់ស្តាប់អ្នក។ ព្រះតែងតែស្តាប់យើងនៅពេលយើងអធិស្ឋាន ។

**ចំរៀង៖** ១. ក្នុងពេលទ្រង់ ២.ទ្រង់ធ្វើឱ្យខ្ញុំសប្បាយ ៣. ខ្ញុំនឹងទុកចិត្តទ្រង់

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត «បញ្ចុកនំ»**



**សម្ភារៈដែលត្រូវការ៖** នំ អំបិល ក្រូចឆ្មារ ម្ទេសម៉ត់ ចាន ក្រមា(សម្រាប់ចងភ្នែក)

១. គ្រូត្រូវយកនំទៅប្រឡាក់ជាមួយ អំបិល ក្រូចឆ្មារ ម្ទេសម៉ត់

២. ចែកកុមារជាពីរក្រុម ហើយជ្រើសរើសកុមារម្នាក់ពីក្រុមនីមួយៗ ហើយចងភ្នែកកុមារនោះ

៣. កុមារទាំងពីរដែលបានរុំភ្នែកហើយនោះ ត្រូវយកនំពីចានម្នាក់មួយ ហើយបញ្ចុកទៅកុមារដែលបានរុំភ្នែកម្នាក់ទៀតនោះ។ កុមារណាដែលអាចញ៉ាំនំអស់មុននោះក្រុមរបស់គេនឹងទទួលបានមួយពិន្ទុ។



៤. បន្តលេងល្បែងនេះរហូតដល់កុមារបានលេងគ្រប់ៗគ្នា។ ក្រុមណាដែលមានពិន្ទុច្រើនជាងក្រុមនោះជាអ្នកឈ្នះ។

៥. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា នំដែលមានរសជាតិខុសៗគ្នា ដូចជាជីវិតនៃការរស់នៅរបស់យើងជួបប្រទះទៅនឹងបញ្ហាខុសៗគ្នា ដែលជួនកាលធ្វើឲ្យយើងសប្បាយចិត្ត កើតទុក្ខ មិនសប្បាយចិត្ត ឬ ខឹង។ ប៉ុន្តែគ្រប់កាលៈទេសៈទាំងអស់ នៅពេលដែលយើងអធិស្ឋានទៅកាន់ព្រះ ទ្រង់នឹងឆ្លើយតបនឹងការអធិស្ឋានរបស់យើង។

## ៤. ការណែនាំមេរៀន

តើអ្នកធ្លាប់យំទេ? ហេតុអ្វីបានជាអ្នកយំ? តើអ្នកកធ្លាប់កើតទុក្ខទេ? តើអ្នកធ្លាប់ឈឺចាប់ទេ? តើអ្នកធ្លាប់ខឹងទេ? មានរឿងជាច្រើននៅក្នុងជីវិតដែលធ្វើឲ្យអ្នកកើតទុក្ខ ឬខឹង។ ប៉ុន្តែទោះបីជាយើងជួបប្រទះនូវស្ថានភាពបែបនោះក៏ដោយ ក៏យើងអាចពឹងផ្អែកលើព្រះបានជានិច្ច ពីព្រោះទ្រង់តែងតែស្តាប់យើងនៅពេលដែលយើងអធិស្ឋាន។ ថ្ងៃនេះយើងនឹងសិក្សាពីបុគ្គលពីរនាក់ដែលបានអធិស្ឋានទៅកាន់ព្រះ ហើយព្រះបានឆ្លើយតបនៅពេលដែលពួកគេជួបប្រទះនឹងការលំបាក។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ថ្ងៃនេះរឿងនៅក្នុងព្រះគម្ពីររបស់យើងគឺនិយាយអំពី គ្រួសារពីរដែលរស់នៅមិនចុះសម្រុងនឹងគ្នា។ សារ៉ា អាប្រា-ហាំ និងអ៊ីសាកគឺជាគ្រួសារមួយ។ សារ៉ា និងអ័ប្រាហាំគឺជាឪពុកម្តាយ ហើយអ៊ីសាកគឺជាកូនប្រុសរបស់ពួកគេ។ អ៊ីសាកគឺមានអាយុប្រហែល ៣ឆ្នាំនៅពេលដែលមានរឿងនេះកើតឡើង។

ឥឡូវនេះអ័ប្រាហាំមានគ្រួសារមួយទៀត។ ជាច្រើនឆ្នាំមុនពេលដែលអ៊ីសាកកើត សារ៉ាមានការព្រួយបារម្ភថា ព្រះនឹងមិនប្រទានកូនឲ្យអ័ប្រាហាំតាមរយៈផ្ទៃរបស់នាង។ ដូច្នេះនាងបានទៅប្រាប់ឲ្យអ័ប្រាហាំឲ្យចាប់ផ្តើមគ្រួសារថ្មីជាមួយអ្នកបម្រើរបស់នាងគឺហាការ។ ហើយអាប្រាហាំក៏មានកូនប្រុសម្នាក់ឈ្មោះ អ៊ីសម៉ាអែល ជាមួយនឹងហាការ ហើយនៅពេលដែលអ៊ីសាកកើត អ៊ីសម៉ាអែលគឺមានវ័យជំទង់ទៅហើយ ។

សារ៉ា និងហាការមិនសូវចុះសម្រុងជាមួយគ្នានោះទេ គឺពួកគេមានការច្រណែនគ្នាទៅវិញទៅមក។ នៅចុងបញ្ចប់សារ៉ាបានប្រាប់អ័ប្រាហាំឲ្យដេញហាការ និងកូនប្រុសរបស់នាងគឺអ៊ីសម៉ាអែលឲ្យចាកចេញឲ្យឆ្ងាយ។ អ័ប្រាហាំមិនដឹងថាគាត់ត្រូវធ្វើបែបណានោះទេ ពីព្រោះគាត់ស្រលាញ់អ៊ីសម៉ាអែលដែលជាកូនប្រុសគាត់។ ប៉ុន្តែគាត់ក៏ស្រលាញ់ សារ៉ា និងកូនប្រុសរបស់គាត់អ៊ីសាកដែរ។ គាត់មិនដឹងថាគាត់ត្រូវធ្វើយ៉ាងណាដើម្បីដោះស្រាយបញ្ហានិងបញ្ឈប់ជម្លោះនេះនោះទេ។

ប៉ុន្តែព្រះបានឮពីការបារម្ភរបស់អ័ប្រាហាំ ហើយទ្រង់បានរៀបចំផែនការមួយ។ ព្រះបានប្រាប់អ័ប្រាហាំកុំឲ្យបារម្ភពីអ៊ីសម៉ាអែលក្នុងការផ្លាស់ទីទៅទីកន្លែងថ្មីនោះឡើយ។ ព្រះបានសន្យាថានឹងការពារដល់អ៊ីសម៉ាអែល។ ដូច្នេះនៅពេលព្រឹកព្រលឹម អ័ប្រាហាំបានខ្ចប់អាហារ និងទឹកមួយចំនួនឲ្យទៅអ៊ីសម៉ាអែល និងហាការ។ ពួកគេបានចេញដំណើរចូលទៅក្នុងទីរហោស្ថាន។

នៅឯទីរហោស្ថានគឺពិតជាក្តៅ និងមានធូលីច្រើនណាស់។ ហាការ និងអ៊ីសម៉ាអែលក៏បានផឹកទឹកដែលអ័ប្រាហាំបានឲ្យពួកគេនោះ។ មិនយូរប៉ុន្មានទឹកនោះក៏អស់ ហើយហាការ និងអ៊ីសម៉ាអែល មានការស្រេកទឹកជាខ្លាំង។ ពួកគេមិនអាចស្វែងរកទឹកបាននោះទេ។ ពួកគេស្រេកទឹកខ្លាំងណាស់ ហើយគេគិតថាគេអាចនឹងស្លាប់ជាមិនខាន។ នៅគ្រប់ទីកន្លែងដែលហាការ និងអ៊ីសម៉ាអែលមើល អ្វីៗដែលពួកគេបានឃើញគឺជាវាលខ្សាច់ដ៏ក្តៅ ស្ងួត និងមានតែធូលីដីប៉ុណ្ណោះ។

អ៊ីសម៉ាអែលមានការស្រេកទឹកជាខ្លាំងហើយក៏ចាប់ផ្តើមយំ។ ម្តាយអ៊ីសម៉ាអែលបានយកគេទៅដាក់នៅក្រោមគុម្ពោតមួយកន្លែងដែលមានម្លប់បន្តិចពីពន្លឺថ្ងៃដ៏ក្តៅ។ វាគឺពិតជាមានការឈឺចាប់ណាស់សម្រាប់ហាការក្នុងការ

ដែលឃើញកូនប្រុសរបស់នាងយំ ហើយនាងមិនអាចជួយអ្វីដល់កូនបាននោះ។ ហាការក៏ចាប់ផ្ដើមយំដែរ។ ប៉ុន្តែព្រះបានឮហាការ និងអ៊ីសម៉ាអែលយំ។ ព្រះបានចូលមកឯហាការ ហើយប្រាប់នាងថា កុំឲ្យខ្លាចឡើយ។ ព្រះអង្គបានប្រាប់នាងថាទ្រង់បានឮអ៊ីសម៉ាអែលយំ ហើយថាទ្រង់នឹងមើលថែគេ។

បន្ទាប់មកព្រះក៏បានបង្ហាញអណ្តូងទឹកមួយដល់ហាការដែលនាងមិនបានឃើញពីមុន។ ហាការ និងអ៊ីសម៉ា-អែលក៏ប្រញាប់ទៅកាន់អណ្តូងទឹកនោះហើយផឹកទឹកហើយផឹកទៀត។ ព្រះបានមើលថែអ៊ីសម៉ាអែលដូចជាអ្វីដែលទ្រង់បានសន្យាជាមួយអ័ប្រាហាំ ទ្រង់នឹងបង្កើតជាតិសាសន៍មួយតាមរយៈអ៊ីសម៉ាអែល។

ព្រះស្រលាញ់យើងខ្លាំងណាស់ ហើយទ្រង់ក៏បានស្តាប់ពីអ្វីដែលយើងបាននិយាយផងដែរ។ ព្រះគឺតែងតែស្តាប់ការអធិស្ឋានរបស់យើងជានិច្ច មិនថាតាមរយៈការសរសើរតម្កើង ការយំ ការសើច ឬក៏ការថ្វាយបង្គំនោះទេ។ ព្រះគឺតែងតែស្តាប់ពួកយើងនៅពេលដែលយើងអធិស្ឋាន ឬក៏មានបន្ទូលទៅកាន់ព្រះអង្គ!

## ៦. សំនួរពិភាក្សា

១. តើអ៊ីសម៉ាអែលគឺជានរណា? *គាត់គឺជាកូនប្រុសរបស់អ័ប្រាហាំ*

២. តើនរណាគឺជាម្តាយរបស់អ៊ីសម៉ាអែល? *ហាការ*

៣. តើមានរឿងអ្វីកើតឡើងនៅក្នុងសាច់រឿងនេះ?
*សារ៉ា និងហាការគឺមិនចូលចិត្តគ្នានោះទេ។ សារ៉ាចង់ឲ្យហាការ និងអ៊ីសម៉ាអែលចេញឲ្យឆ្ងាយ*

៤. ហេតុអ្វីបានជាព្រះមកជួយដល់ហាការ និងអ៊ីសម៉ាអែល? *ព្រោះទ្រង់បានឮពួកគេយំ ហើយទ្រង់ក៏បានសន្យាជាមួយអ័ប្រាហាំថានឹងការពារដល់អ៊ីសម៉ាអែលផងដែរ*

៥. តើអ្នកអាចធ្វើអ្វីបាននៅពេលជួបការលំបាក? *អធិស្ឋានទៅកាន់ព្រះ*

## ៧. ល្បែងកំសាន្ត «ញ៉ាំម្ហូរធ្វើមុខញញឹម»




**សម្ភារៈដែលត្រូវការ៖** អំបិលម្ទេស និងម្ហូរ តុ១ កៅអី២

១. ចែកកុមារជាពីរក្រុម

២. គ្រូត្រូវដាក់ម្ហូរ អំបិលម្ទេស ហើយដាក់វានៅលើតុ

៣. ជ្រើសរើសតំណាងក្រុមម្នាក់ពីក្រុមទាំងពីរ មកអង្គុយលើកៅអីទល់មុខគ្នា

៤. នៅពេលដែលគ្រូនិយាយ "១ ២ ៣" ពួកគេត្រូវញ៉ាំម្ហូរណាមួយក៏បាន ដោយជ្រលក់ជាមួយអំបិលម្ទេស ។ ហើយគេត្រូវតែញ៉ាំវាដោយទឹកមុខញញឹម។ ប្រសិនបើកុមារណាម្នាក់ជ្រួញចិញ្ចើម ឬក៏ខ្ជាក់វាចេញ នោះគេនឹងចាញ់ល្បែងនេះ។

៥. បន្តលេងល្បែងនេះរហូតដល់កុមារបានលេងគ្រប់ៗគ្នា។ ក្រុមណាដែលមានពិន្ទុច្រើនជាងនោះក្រុមរបស់ពួក-គេនឹងឈ្នះល្បែងនេះ។

៦. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ជីវិតរស់នៅរបស់យើងគឺមិនតែងតែងាយស្រួលរហូតនោះទេ។ ប៉ុន្តែពួកយើងនៅតែអាចមានអំណរពីព្រោះព្រះតែងតែស្តាប់ឮពីសេចក្តីអធិស្ឋានរបស់យើងជានិច្ច។

**៨. ខគម្ពីរចងចាំ** យ៉ូហាន ១៥:៧

**៩. ហត្ថកម្ម** «ព្រះស្តាប់យើងនៅពេលដែលយើងអធិស្ឋាន»

**សម្ភារៈដែលត្រូវការ៖** ព្រីនក្រដាសហត្ថកម្ម និងកូល័រ



១. ផាត់ពណ៌រូបអ៊ីសម៉ាអែលនិងហាការ

២. គូរូបព្រះនៅចន្លោះអ៊ីសម៉ាអែលនិងហាការ ដែលបានឮការអធិស្ឋានរបស់ពួកគេ និងមកជួយដល់ពួកគេផងដែរ។

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

# ព្រះសណ្ដាប់យើង ពេលយើងអធិស្ឋាន



ការណែនាំ៖

១. ដាក់ពណ៌រូបអ៊ីសម៉ាអែល និងហាការ

២. គូសរូបព្រះនៅចន្លោះអ៊ីសម៉ាអែល និងហាការ ដែលបានឮការអធិស្ឋានរបស់ពួកគេ និងបានមកជួយដល់ពួកគេផងដែរ។